# បណ្ណាល័យ វបសអ និង មណ្ឌលព័ត៌មានបឹងទន្លេសាប



## ការបង្កើតមណ្ឌលព័ត៌មានបឹងទន្លេសាប

គេតែងអធិប្បាយពីបឹងទន្លេសាប ដែលមានធនធានសំបូរស្ដុកស្ដម ថាជាសរសៃឈាមនៃប្រទេសកម្ពុជា ។ ដូចគ្នាដែរ បណ្ណាល័យ ដែលសំបូរឯកសារក៏ត្រូវគេចាត់ទុកថាជាសសៃឈាមនៃវិទ្យាស្ថានស្រាវជ្រាវដ៏សក្តិសិទ្ធិដែរ ។ ការបង្កើតមណ្ឌលព័តិមានបឹងទន្លេសាប (TSI) នៅក្នុងបណ្ណាល័យនៃវិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា (វបសអ) ធ្វើឡើងក្នុងចន្លោះពេលពីដើមខែមករា ដល់ចុងខែមិថុនា ២០០៦ ដោយបានទទួលជំនួយហិរញ្ញវត្ថុពីធនាគារអភិវឌ្ឍន៏អាស៊ី (ADB) ។

មណ្ឌលព័តិមានបឹងទន្លេសាប ក្រោមកិច្ចផ្ដួចផ្ដើមពី ADB បានចាប់ផ្ដើមធ្វើក្នុងឆ្នាំ២០០២ ក្នុងលក្ខណៈជាគំរោងដៃគូគ្នា រវាងអង្គការ និងបុគ្គលនានា ដែលធ្វើការងារដើម្បីជំរុញការអភិវឌ្ឍន៏សេដ្ឋកិច្ចមានចីរភាពនៅតំបន់អាងទន្លេសាប និងតំបន់ជុំវិញ ។ គំរោងរយៈពេល ១០ឆ្នាំនេះ មានទិសដៅការពារធនធានដ៏វិសេសនៃបឹងទន្លេសាប និងជួយឱ្យប្រជាជនកម្ពុជាបានយល់ដឹងកាន់តែច្បាស់ពីធនធានដ៏មានតំលៃរបស់កម្ពុជា ។ វបសអ រីករាយណាស់ដោយបានចូលរួមក្នុងកម្មវិធីនេះ ដើម្បីផ្ដល់ឱ្យអ្នកស្រាវជ្រាវ និងសាធារណជនទូទៅ នូវព័តិមាន និងលទ្ធផលនៃការងារអភិវឌ្ឍន៏ជាច្រើនរបស់មណ្ឌលព័តិមានបឹងទន្លេសាប ។

មណ្ឌលព័តិមានបឹងទន្លេសាបថ្មីនេះ ត្រូវបានបង្កើតឡើងជាចំណែកមួយនៃបណ្ណាល័យ វបសអ ដើម្បីបំរើការងារកសាងសមត្ថភាពនៃកម្មវិធីផ្ដល់ព័តិមានបឹងទន្លេសាប ។ ធនធាននៃមណ្ឌលព័តិមានបឹងទន្លេសាប វាបំពេញបន្ថែមទៅលើលទ្ធភាព និងបណ្ដាញការងារដែលមានស្រាប់នៅ វបសអ និងជាចំណែកមួយនៃសកម្មភាពដែល វបសអ កំពុងអនុវត្ត ។ ធនធានដ៏មានតម្លៃនៅបណ្ណាល័យ វបសអ សព្វថ្ងៃ រួមមានបណ្ដុំសព្វគ្រប់នៃឯកសារបោះពុម្ពទាំងអស់របស់ វបសអ ព្រមទាំងបណ្ដុំឯកសារពិសេសៗ ដូចជា :

- បណ្ណាល័យឯកសារធនាគារអភិវឌ្ឍន៏អាស៊ី
- បណ្ដុំឯកសារវិទ្យាស្ថានស្រាវជ្រាវសហប្រជាជាតិ ដើម្បីការអភិវឌ្ឍន៏សង្គម
- បណ្ដុំឯកសារនៃគម្រោងអន្តរស្ថាប័នសហប្រជាជាតិ ស្ដីពីការជួញដូរមនុស្ស
- បណ្ណាល័យធនាគារពិភពលោក

ធនធានឯកសារទាំងនេះ ត្រូវបានបង្កើនឡើងយ៉ាងទៀងទាត់ ហើយវាជួយឱ្យបណ្ណាល័យ វបសអ មានបណ្ដុំឯកសារប្រសើរជាងគេ ពាក់ព័ន្ធនឹងការអភិវឌ្ឍន៏នៅកម្ពុជា ។

ក្នុងអំឡុងពេលបង្កើតមណ្ឌលព័តិមាន បុគ្គលិកបណ្ណាល័យ វបសអ បានធ្វើការរួមគ្នាកសាងបណ្ដុំឯកសារ ដោយដាក់បញ្ចូលព័តិមានថ្មីៗទៀត ជាពិសេស ឯកសារទាក់ទងនឹងកម្មវិធីព័តិមានបឹងទន្លេសាប និងតំបន់ទីជំរាលអាងទន្លេសាប ។ បុគ្គលិកបណ្ណាល័យ បានធ្វើទស្សនកិច្ចជាទៀងទាត់នៅតាមស្ថាប័ននានា ដើម្បីប្រមូលធនធានបន្ថែមសំរាប់បណ្ណាល័យ ដូចជា សៀវភៅ ប័ណ្ណផ្សព្វផ្សាយ ស៊ីឌីរ៉ូម និងផែនទី ។ម្យ៉ាងទៀត ពួកគេបានចំណាយពេលច្រើនណាស់ ដើម្បីស្វែងរកឯកសារផ្សេងៗ ដែលមានលើអ៊ិនធឺណិត ។ ធនធានទាំងអស់នេះ បានដាក់បញ្ចូលទៅក្នុងកាតាឡុកថ្មី លើអ៊ិនធឺណិតនៃឯកសារក្នុងបណ្ណាល័យ វបសអ សំរាប់ឱ្យសាធារណជនមានលទ្ធភាពប្រើប្រាស់វាបានយ៉ាងងាយស្រួល ។

ឯកសារសំខាន់ៗនៅក្នុងមណ្ឌលព័តិមាន រួមមាន :

- អត្ថបទផ្សេងៗ របស់ ADB ស្ដីពីតំបន់បឹងទន្លេសាប
- ប្រព័ន្ធទិន្នន័យជីវមណ្ឌលនៅទន្លេសាប
- ប្រព័ន្ធទិន្នន័យស្ដីពីរបាយការណ៏ទាក់ទងនឹង TSI
- សៀវភៅ ទស្សនាវដ្ដី និងឯកសារទាក់ទងនឹងអាងទន្លេសាប
- សៀវភៅ និងប័ណ្ណផ្សព្វផ្សាយ របស់ ADB ស្ដីពី TSI
- ផែនទី
- ឯកសារផ្សព្វផ្សាយជាស៊ីឌីរ៉ូម របស់ ADB គណៈកម្មាធិការទន្លេមេគង្គ (MRC) និងអង្គការផ្សេងៗទៀត
- ឯកសារបោះពុម្ពរបស់ World Fish Centre
- ឯកសារបោះពុម្ពរបស់គណៈកម្មាធិការទន្លេមេគង្គ
- ឯកសារដាក់លើអ៊ិនធឺណិត
- របាយការណ៏ស្រាវជ្រាវ និងនិក្ខេបបទ

## ការតុបតែងបណ្ណាល័យជាថ្មី និងបំពាក់គ្រឿងបន្ថែម

ក្រុមការងារបណ្ណាល័យ ដែលរួមមានលោក ហឹ ហ៊ិន លោកស្រី អ៊ុន ស៊ីណុច និងកញ្ញា ស៊ន ម៉ាដែន រួមជាមួយទីប្រឹក្សា និងអ្នកស្ម័គ្រចិត្ត បានធ្វើការរួមគ្នារៀបចំកែលំអបណ្ណាល័យឡើងវិញ ដោយបំពាក់ឧបករណ៏ គ្រឿងសង្ហារឹម និងរបស់ប្រើប្រាស់ថ្មីៗមួយចំនួន ។ ការរៀបចំជាថ្មី បានជួយបណ្ណាល័យ

ឱ្យផ្តល់សេវាបានកាន់តែប្រសើរ ហើយក្នុងពេលជាមួយគ្នាក៏ផ្តោតការយកចិត្តទុកដាក់ចំពោះមណ្ឌលព័ត៌មានបឹងទន្លេសាប ក្រោមជំនួយឧបត្ថម្ភរបស់ ADB ដែលជាផ្នែកដ៏សំខាន់មួយនៃបណ្ណាល័យ ។

ក្រៅពីកំណែលំអរបៀបរៀបចំបណ្ណាល័យ ក៏មានការដាក់សញ្ញាសំគាល់ជាច្រើនបន្ថែមទៀត ដើម្បីជួយដល់អ្នកមកបណ្ណាល័យ ឱ្យងាយស្រួលក្នុងការរកឯកសារតាមវិស័យនីមួយៗ ។ ម្យ៉ាងទៀត បានដាក់ប្រើកុំព្យូទ័រ ៤គ្រឿង សំរាប់ឱ្យអ្នកមកបណ្ណាល័យ ស្រាវជ្រាវរកឯកសារតាមកម្មវិធី OPAC ក្នុងនេះកុំព្យូទ័រ ២គ្រឿងបានភ្ជាប់នឹងអ៊ីនធឺណិត ។ នៅគ្រប់ពេលតែងមានទីប្រឹក្សាមួយរូបប្រចាំការ សំរាប់ជួយដល់អ្នកអានក្នុងការស្វែងរកឯកសារ និងជួយណែនាំពីប្រព័ន្ធក្នុងបណ្ណាល័យផងដែរ ។

## ប្រព័ន្ធ NewGenLib

បណ្ណាល័យទំនើបៗ និងមណ្ឌលព័ត៌មាន អាចផ្តល់លទ្ធភាពខ្ពស់ ក្នុងការស្វែងរកព័ត៌មាន តាមរយៈការប្រើប្រាស់ សូហ្វវែរសំរាប់គ្រប់គ្រងប្រព័ន្ធបណ្ណាល័យ ។ ក្នុងករណីភាគច្រើន សូហ្វវែរនេះមានតម្លៃខ្ពស់ ហើយបណ្ណាល័យជាច្រើន នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ពុំមានលទ្ធភាពទិញវាមកប្រើប្រាស់ទេ ។ វិបសអ បានជាវប្រព័ន្ធគ្រប់គ្រងបណ្ណាល័យដ៏ទំនើបជា "បច្ចេកវិទ្យាឈានមុខ" ហៅថាប្រព័ន្ធ NewGenLib ដែលជាចំណុចស្នូលនៃការអភិវឌ្ឍន៍បណ្ណាល័យ និងការបង្កើតមណ្ឌលព័ត៌មានបឹងទន្លេសាប ។ បុគ្គលិក វិបសអ បានប្រើប្រាស់ប្រព័ន្ធ NewGenLib នេះសំរាប់គ្រប់គ្រងប្រព័ន្ធជាប់ពាក់ព័ន្ធទាំងអស់ រួមទាំង ឯកសារទទួលបាន ការចែកចាយទៅឱ្យអ្នកខ្ចី បញ្ជីឈ្មោះឯកសារ និងកាតាឡុកលើអ៊ីនធឺណិត (OPAC) ។ ប្រព័ន្ធ NewGenLib បានបង្កើតឡើងនៅប្រទេសឥណ្ឌា ដោយប្រើបច្ចេកវិទ្យាមានប្រភពបើកទូលាយ ដើម្បីផលិតកម្មវិធីប្រព័ន្ធគ្រប់គ្រងបណ្ណាល័យតាមស្តង់ដារអន្តរជាតិមួយសំរាប់ប្រទេសកំពុងអភិវឌ្ឍន៍ ។ ប្រព័ន្ធថ្មីនេះមានចំនុចពិសេសជាច្រើន ដែលជួយដល់បុគ្គលិកក្នុងការផ្តល់ "គុណភាពបន្ថែម" ដល់អ្នកប្រើប្រាស់សេវាបណ្ណាល័យ ។ ប្រព័ន្ធ NewGenLib ផ្តល់លទ្ធភាពឱ្យរកបានដោយងាយនូវធនធានគ្រប់បែបយ៉ាង មានទាំង សៀវភៅនៅលើធ្នើ ទូ ឯកសារលើអ៊ីនធឺណិត ឬឯកសារជាឌីជីថល ដែលមាននៅតាមកន្លែងផ្សេងៗទៀត ក៏ដូចជាព័ត៌មានលំអិតជាងមុនលើឯកសារនីមួយៗ ។

ដើម្បីជួយសំរួលដល់ការប្រើប្រាស់ប្រព័ន្ធ NewGenLib នៅក្នុងបណ្ណាល័យ វិបសអ ក្រុមការងារបណ្ណាល័យបានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយលោក ឡឹង វណ្ណា ប្រធានផ្នែកបច្ចេកវិទ្យាព័ត៌មាន (IT) របស់ វិបសអ និងក្រុម NewGenLib នៅឥណ្ឌា ។ មុនពេលធ្វើការផ្លាស់ប្តូរកម្មវិធី បញ្ជីឯកសារជាឌីជីថល ដែលប្រើកម្មវិធី WINISIS បានផ្ញើទៅកាន់ប្រទេសឥណ្ឌា ដើម្បីបំលែងកំណត់ត្រាឯកសារ ទៅជារចនាសម្ព័ន្ធស្តង់ដារអន្តរជាតិ MARC 21 សំរាប់ត្រៀមតំលើងប្រព័ន្ធ NewGenLib ។ កុំព្យូទ័រថ្មីៗ និង server ក៏បានទិញ និងដាក់តំលើងកាលពីចុងខែមីនាដែរ ។

លោក Meher Siddhartha វិស្វករផ្នែកប្រព័ន្ធ NewGenLib បានមកធ្វើទស្សនកិច្ច ២សប្តាហ៍ នៅ វិបសអ កាលពីចុងខែមីនា ២០០៦ ដើម្បីតំលើងសូហ្វវែរ និងបណ្តុះបណ្តាលដល់ប្រធានផ្នែក IT និងបុគ្គលិកបណ្ណាល័យ វិបសអ ក្នុងការប្រើប្រាស់ និងគ្រប់គ្រងប្រព័ន្ធថ្មី ។ បណ្ណាល័យបានបិទទ្វារអស់ ២សប្តាហ៍ ក្នុងពេលមានការបណ្តុះបណ្តាលពីប្រព័ន្ធ NewGenLib ។ ក្រោយការបណ្តុះបណ្តាលពីប្រព័ន្ធ NewGenLib បុគ្គលិកបណ្ណាល័យ រួមជាមួយអ្នកស្ម័គ្រចិត្ត និងបុគ្គលិកអំណែត បានធ្វើការងារយ៉ាងខ្លាំងក្លា ដើម្បីដាក់លេខកូដសៀវភៅ និងរៀបចំកំណត់ត្រាបញ្ជីឈ្មោះសៀវភៅសំរាប់ចែកចាយឱ្យបានត្រឹមត្រូវ ។ ការកសាងបណ្តុំឯកសារកំពុងបន្តទៅមុខទៀត ហើយបុគ្គលិកមានការយល់ដឹងកាន់តែច្រើនពី ប្រភេទឯកសារដែលត្រូវមានដើម្បីឱ្យបណ្តុំឯកសារមានលក្ខណៈពាក់ព័ន្ធនឹងតំរូវការ ។ បុគ្គលិកទាំងអស់បន្តការរៀនសូត្រពីជំនាញថ្មី ដោយផ្តោតការប្រឹងអភិវឌ្ឍន៍សមត្ថភាពខ្លួនក្នុងការរៀបចំបញ្ជីឈ្មោះ និងធ្វើចំណាត់ថ្នាក់សៀវភៅ ដោយមានការជួយណែនាំពីទីប្រឹក្សាបណ្ណាល័យ ។

## បណ្ណាល័យរៀបចំថ្មី



បណ្ណាល័យរៀបចំថ្មីរបស់ វិបសអ ដែលមានរួមបញ្ចូលទាំងមណ្ឌលព័ត៌មានបឹងទន្លេសាបផង គឺជាកន្លែងទាក់ទាញ និងជាទីចំណាប់អារម្មណ៍នៃមិត្តអ្នកអាន ។ បណ្ណាល័យផ្តល់ឱ្យអ្នកប្រើប្រាស់នូវព័ត៌មានសំខាន់ៗទាក់ទងនឹងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ជាពិសេសព័ត៌មានស្តីពីទន្លេសាប ក្រោមជំនួយឧបត្ថម្ភរបស់ ADB ។ ការកែលំអសេវាបណ្ណាល័យរួមមានទាំង ការដាក់សញ្ញាសំគាល់តាមប្រព័ន្ធ Dewey Decimal System ការដាក់តុធ្វើការរបស់ទីប្រឹក្សា អ្នកអាននៅកន្លែងសាធារណៈ ការបង្កើតកាតាឡុកលើអ៊ីនធឺណិត (OPAC) និងបណ្តុំឯកសារយោង ។ បុគ្គលិកបណ្ណាល័យបានរៀនសូត្រជំនាញថ្មី និងបានទទួលស្វាគមន៍ភ្ញៀវថ្មីៗជាច្រើននាក់ ដែលមកអានឯកសារ រឺជាអ្នកស្រាវជ្រាវជារៀងរាល់ថ្ងៃ ។